# ទស្សនវិស័យរបស់ក្រុមហ៊ុនខេមផេសខន់ត្រូល

## CAMPESTCONTROL PERSPECTIVES

(UPDATED BY TECHNICAL ADVISERY TEAM ON 30/01/2011)

សេវាកម្មដើម្បីមោទនៈជាតិខ្មែរ

CAMPESTCONTROL

<u>អាស័យដ្ឋាន</u>:
អគារលេខ ២១៦ ហាស់
ផ្លូវ ៦៣ សង្កាត់បឹងកេងកង១
ខណ្ឌចំការមន រាជធានីភ្នំពេញ
<u>ADDRESS</u>: #216H, 63St.,
BEUNGKENKANG I,
CHAMCARMORN, PHNOM PENH,
KINGDOM OF CAMBODIA
TEL: (855)12 943434/
FAX: (855)23216655

ខេមផេសខន់ត្រូល **(CAMPESTCONTROL)** ជាក្រុមហ៊ុនឯកទេសកម្មក្នុងការងារកំចាត់សមាសភាពចង្រៃ ដែលទើបបានកែសម្រួលពីសេវា ខេម.ភីស៊ីអេស_ **CamPCS** (តាំងពីឆ្នាំ ១៩៩៥) ក្នុងគោលបំណងលើកកំពស់អនុលោមភាពតាមលក្ខខ័ណតម្រូវនៃនិតិវិធីជាតិ ស្តង់ដារតំបន់ និងស្តង់ដារអន្តរជាតិ ក្នុងបរិបទនៃអង្គការពាណិជ្ជកម្មអន្តរជាតិ និង អង្គការសុខភាពពិភពលោក។ ខេមផេសខន់ត្រូល ជាក្រុមហ៊ុន ដែលប្រមូលផ្តុំដោយ គំនិត និងបទពិសោធន៍ របស់អ្នកឯកទេសខ្មែរជើងចាស់ ដើម្បីមោទនជាតិខ្មែរ រក្សាប្រយោជន៍ជាតិខ្មែរ និងទទួលខុសត្រូវលើធនធានធម្មជាតិ និងបរិស្ថានជាតិខ្មែរ។ សេវាកម្មកំចាត់សត្វល្អិត ខេម.ភីស៊ីអេស ត្រូវបាន និងកំពុងទទួលការគាំទ្រ និងទទួលស្គាល់ពីអ្នកប្រើសេវាក្នុងប្រទេស និង ពីរាល់ប្រទេសនាំចូលដែលជាដៃគូរពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្នុងទិសដៅលើកកំពស់ស្តង់ដារសេវាកម្ម ក៏ដូចជាដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល (ពិសេសជំរុញការនាំចេញអង្ករ) នោះសេវាកម្មកំចាត់សត្វល្អិត នៃក្រុមហ៊ុនខេមផេសខន់ត្រូល បានកំណត់ទស្សនៈវិស័យដូចខាងក្រោម:

❶ **និត្យានុកូលភាព (Legality) :** ក្នុងទស្សនៈវិស័យនេះ ក្រុមហ៊ុនខេមផេសខន់ត្រូល ប្រកាន់ខ្ជាប់លើគោលការជាកតព្វកិច្ចដែលកំណត់ដោយរាល់និតិវិធីជាតិជាធរមាន។ ដើម្បីទទួលបាននូវនិត្យានុកូលភាពក្នុងការផ្តល់សេវា ដោយរាប់បញ្ចូលទាំងកិច្ចចុះបញ្ជី ការបង់ប៉ាតង់ ការចុះបញ្ជិកា និតិវិធីគ្រប់គ្រងធាតុចូលដែលប្រើក្នុងការផ្តល់សេវា (ថ្នាំកសិកម្ម សារធាតុបំផ្លាញស្រទាប់អូសូន ជាដើម) វិធីសាស្រ្តកំចាត់សមាសភាពចង្រៃ ការគ្រប់គ្រងសំណល់ពីសេវា និងវិតិវិធីដទៃទៀតដែលបានកំណត់ និង នឹងកំណត់ដោយនិតិវិធីនៃព្រះរាជាណាចក្រកម្ពុជា។ និតិវិធីជាតិត្រូវកំណត់ជាអត្ថិភាពក្នុងជំរើសអនុវត្តដើម្បីតម្រូវតាមលក្ខខ័ណស្តង់ដារអន្តរជាតិ (ឧទាហរណ៍: ការប្រើមេទីលប្រូម៉ាយ ត្រូវបានហាមឃាត់ដោយនិតិវិធី តែអាចប្រើប្រព្រឹត្តិកម្មកំដៅដើម្បីរំងាប់ការចំលងសមាសភាពចង្រៃ តាមសំភារៈវេចខ្ចប់អំពីឈើ ដែលក៏ជាជំរើសមួយកំណត់ដោយស្តង់ដារអន្តរជាតិ នៃវិធានការភូតគាមអនាម័យលេខ១៥)។

❷ **បមាណីអន្តរជាតូបនីយកម្ម (International Standardization):** ពាក់ព័ន្ធទៅនឹងការអនុវត្តវិធានការ កំចាត់សមាសភាពចង្រៃ ដែលជាសេវាឯកទេសកម្មរបស់ក្រុមហ៊ុនខេមផេសខន់ត្រូល នោះមានស្តង់ដារអន្តរជាតិពាក់ព័ន្ធជាច្រើន (រាប់ទាំងស្តង់ដារតំបន់ និង លក្ខខ័ណតម្រូវដោយឡែក របស់ប្រទេសនាំចូល) ដែលក្រុមហ៊ុនប្រើប្រាស់ជាគោលក្នុងការប្រតិបត្តិផ្តល់សេវា។ ការប្រកាន់ខ្ជាប់បែបនេះ ក្នុងគោលបំណងរក្សាបាននូវប្រសិទ្ធភាពនិងសុវត្ថភាពសេវា ការការពារសុខភាពអ្នកពាក់ព័ន្ធ ការពារធនធានធម្មជាតិ និងបរិស្ថាន និងទទួលបាននូវអនុលោមភាពតាមលក្ខខ័ណតម្រូវនៃប្រទេសនាំចូល។ បណ្តាស្តង់ដារ គោលទាំងនោះ មានជាអាទិ៍:

- គោលការណែនាំក្នុងការចែកចាយ និងប្រើប្រាស់ថ្នាំកសិកម្ម (FAO, 2006)

- កិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក
- បណ្ណាស្តង់ដារអន្តរជាតិនៃវិធានការភូតគាមអនាម័យ ដែលអនុម័តដោយអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ
- បណ្ណាអនុសញ្ញាអន្តរជាតិគ្រប់គ្រងថ្នាំកសិកម្ម (POP, PIC, Montreal Protocol, etc.)

❸ **គោរពបទដ្ឋានបច្ចេកទេស (Technical Respect):** គោលការចំបងនៃបទដ្ឋានបច្ចេកទេសក្នុងវិធានការកំចាត់សមាសភាពចង្រៃ គឺ ប្រសិទ្ធភាពលើគោលដៅនៃការកំចាត់ មិនមានផលប៉ះពាល់លើកម្មវត្ថុក្រៅពីគោលដៅ សុវត្ថភាពចំពោះអ្នកពាក់ព័ន្ធ មិនបង្កឱ្យមានការកើតឡើងនូវភាព ធន់ទ្រាំក្នុងចំណោមប្រជាករសមាសភាពចង្រៃ និង សំខាន់គឺស្របតាមការចង់បានរបស់អ្នកប្រើប្រាស់ ឬ អនុលោមតាមលក្ខខ័ណតម្រូវនៃរដ្ឋាភិបាលប្រទេសនាំចូល (ដែលកំណត់ដោយស្តង់ដារជាតិ និង អន្តរជាតិ)។ ដើម្បីសម្រេចគោលដៅទាំងអស់នេះ ធ្វើឱ្យកំរៃសេវា ខេមផេសខន់ត្រូល ដែលជាសេវាឯកទេសកម្ម តែងមាន តំលៃខ្ពស់ជាង សេវាកម្មដទៃ (សេវាចម្រុះ ដែលមានទាំងបោសសំអាត ឃ្លាំង ដឹក ជញ្ជូន ជាដើម) នៅក្នុងប្រទេសកម្ពុជា ដែលគិតគូរជាសំខាន់ តែលើប្រសិទភាពតែមួយមុខ។

❹ **បំរើការដោយបុគ្គលិកខ្មែរ (Khmer Employees):** សេវាកំចាត់សត្វល្អិតរបស់ក្រុមហ៊ុនខេមផេសខន់ត្រូល ត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយក្រុមមន្ត្រីបច្ចេកទេស និងអ្នកឯកទេសខ្មែរជើងចាស់ដែលចូលនិវត្ត ដោយមានបណ្តាញចូលរួមផ្តល់ប្រឹក្សាពីបណ្តាអ្នកឯកទេសខ្មែរនៅក្រៅប្រទេស និងក្នុងប្រទេស។ សេវាកម្មនេះកំពុងប្រតិបត្តិដោយបុគ្គលិកខ្មែរ សុទសាធ ដែលទទួលការបំពាក់បំប៉នត្រឹមត្រូវ និងមានឆន្ទៈចូលរួមដើម្បីលើកកំពស់មោទនជាតិខ្មែរ។

❺ **ចូលរួមបង្កើនការយល់ដឹងជាសាធារណៈ (Sharing in Awareness raising):** ការចូលរួមលើកកំពស់ការយល់ដឹង ដល់សាធារណជន (ពិសេសដល់អ្នកដែលត្រូវប្រើប្រាស់សេវា)អំពីនិត្យានុកូលភាព លក្ខខ័ណតម្រូវឬស្តង់ដារអន្តរជាតិ និងបទដ្ឋានបច្ចេកទេសក្នុងការកំចាត់សមាសភាពចង្រៃ (១).ជាការបង្កើនអតិថិជនដែលប្រើសេវាឯកទេសកម្មកំចាត់សត្វល្អិតរបស់ក្រុមហ៊ុនខេមផេសខន់ត្រូល (២).ជាការចូលរួមលើកកំពស់សុខុមាលភាពសង្គម (៣).ជាជំនួយដល់ការជំរុញឱ្យឆាប់រហ័ស និងសម្រេចជោគជ័យ ប្រកបដោយ និរន្តរភាពក្នុងការនាំចេញរបស់កម្ពុជា។

❻ **រក្សាគាំពារសុខភាពកម្មករ (Worker Health Care):** ក្នុងប្រតិបត្តិការបច្ចេកទេសកំចាត់សមាសភាពចង្រៃ តែងមានការប្រឈមនឹងហានិភ័យចំពោះសុខភាពបុគ្គលិក កម្មករ។ ហេតុនេះក្នុងពេលជ្រើសរើសចូលបំរើការងារនោះការកំណត់អាយុ កាយសម្បទារ ស្ថានភាពសុខភាព ស្របតាមច្បាប់ការងារជាបញ្ហាចាំបាច់។ ក្នុងកំឡុងពេលបំរើការពួកគេត្រូវតែទទួលបាននូវការពិនិត្យសុខភាពជាប្រចាំ កំរៃថៃបំប៉នសុខភាព និងព្យាបាល សំភារៈការពារសុវត្ថភាពផ្ទាល់ខ្លួនគ្រប់គ្រាន់ និងត្រឹមត្រូវ និងម៉ោងការងារតែ ៤ម៉ោងក្នុង១ថ្ងៃ សំរាប់ប្រតិបត្តិការដែលមានកំរិតហានិភ័យខ្ពស់។

❼ **រក្សាគាំពារសុខភាពអ្នកពាក់ព័ន្ធ និងបរិស្ថាន (Stakeholders & Environment Protection):** ការប្រកាន់ខ្ជាប់នូវនិត្យានុកូលភាព បមាណីអន្តរជាតិ បទដ្ឋានបច្ចេកទេស និងចូលរួមបង្កើនការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធ អំពីប្រតិបត្តិការបច្ចេកទេសកំចាត់សមាសភាពចង្រៃ ពិតជាការចូលរួមរក្សាគាំពារសុខភាពអ្នកពាក់ព័ន្ធ និងបរិស្ថាន។ ការជ្រើសរើសប្រើប្រាស់ធាតុចូល វិធីសាស្រ្តប្រតិបត្ត ការបោះបង់ចោលនូវសំណល់ ដែលមានសង្គតភាពទៅនឹងលក្ខខ័ណតម្រូវដោយច្បាប់ជាតិ និងស្តង់ដារ_គោលការណ៍ណែនាំជាអន្តរជាតិ ជាមូលដ្ឋានសំខាន់ក្នុងទស្សនៈវិស័យនេះ។ សុវត្ថភាពត្រូវឈរជាអត្ថិភាពចំបងក្នុងការផ្តល់សេវា របស់ក្រុមហ៊ុនខេមផេសខន់ត្រូល។